# វង់បាញ់ ?

តាម ធម្មតា គេ តែងតែ ដាក់ វង់បាញ់ នៅ ខាង មុខ សំរាប់ បាញ់។ នៅ ក្នុង បរិបទ នយោបាយ នៅ ស្រុក ខ្មែរ សព្វ ថ្ងៃ វង់ បាញ់ របស់ អ្នក ប្រជាធិបតេយ្យ គឺ អំណាច ផ្តាច់ការ, ដូច្នេះ ត្រូវ បាញ់ ចម្រុះ ទៅ កាន់ វង់បាញ់ នោះ ព្រោះ វា ជា តក្កភាព (logique)។ គោលដៅ នៃ ការបាញ់ គឺ ដើម្បី ផ្តួល អំណាច ផ្តាច់ ការ មិន មែន ផ្តួល របប នយោបាយ ដែល មាន ចែង នៅ ក្នុង រដ្ឋធម្មនុញ្ញ។ ជន ណា ដែល ការពារ អំណាច ផ្តាច់ការ គឺ ស្ថិត នៅ លើ វង់បាញ់ នោះ។ អាវុធ ប្រើ សំរាប់ បាញ់ គឺ ប្រជាធិបតី ដូច្នេះ វា ជា អាវុធ អហិង្សា ឬ សន្តិវិធី។ សម រង្ស៊ី មិន មែន ជា ជន ឈរ បាំង វង់បាញ់ ឬ ស្ថិត នៅ លើ វង់បាញ់ នោះ ទេ, ដូច្នេះ វា គ្មាន ហេតុផល អ្វី ដែល ទុក គាត់ ជា បុគ្គល-វង់បាញ់ នោះ ឡើយ ហើយ ក៏ មិន មែន ជា កាល ដែល ត្រូវ ជ្រើស រវាង កឹម សុខា និង សម រង្ស៊ី នោះ ដែរ បើ គ្មាន ការប្រកាស ឬ សកម្មភាព ជា ផ្លូវការ ណា មួយ របស់ កឹម សុខា ដែល វា ផ្ទុយ ស្រឡះ ពី សកម្មភាព តស៊ូ អហិង្សា របស់ អ្នក ប្រជាធិបតេយ្យ។ ជម្រើស រវាង អ្នក ទាំង ពីរ នេះ នៅ ក្នុង កាលៈទេសៈ សព្វ ថ្ងៃ វា គ្មាន បង្កើត នូវ ប្រាជ្ញា និង កម្លាំង អ្វី ដល់ ការតស៊ូ អហិង្សា ប្រឆាំង នឹង អំណាច ផ្តាច់ការ ដែល កំពុង ប្រើ គ្រប់ មធ្យោបាយ : ចិត្តសាស្ត្រ, កម្លាំង កង ប្រដាប់ អាវុធ និង តុលាការ សំរាប់ វាយ ប្រហារ កម្លាំង របស់ អ្នក ប្រជាធិបតេយ្យ។ ដូច្នេះ ការច្រឡំ វង់បាញ់ វា គឺ ជា ការ ធ្វើ អត្តឃាតកម្ម៕

ឧប សៅ សទ្ធា　　　　　　　　　តំនិត　　　　　　　　　២ ធ្នូ ២០១៩